# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៧៤ សសរ

## សេចក្ដីសម្រេច

ស្ដីពី

ការបង្កើតគណៈកម្មការរៀបចំពិធីបុណ្យបញ្ចុះខណ្ឌសីមាព្រះវិហារ សម្ពោធឆ្លងសមិទ្ធផលនានា និងស្រោចស្រពព្រះសុគន្ធវារីប្រគេនសម្ដេចព្រះសង្ឃនាយករង ចំនួន ០២ ព្រះអង្គ នៃគណៈធម្មយុត្តិកនិកាយ នៃព្រះរាជាណាចក្រកម្ពុជា

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃទីស្ដីការគណៈរដ្ឋមន្ត្រី
- យោងតាមតម្រូវការចាំបាច់របស់រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

## សម្រេច

**ប្រការ ១** ៖ ត្រូវបានបង្កើតគណៈកម្មការរៀបចំពិធីបុណ្យបញ្ចុះខណ្ឌសីមាព្រះវិហារ និងសម្ពោធឆ្លងសមិទ្ធផលនានា ដែលជាសមិទ្ធផលដ៏ថ្លៃថ្លារបស់សម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី និងសម្ដេចកិត្តិព្រឹទ្ធបណ្ឌិត **ប៊ុន រ៉ានី ហ៊ុន សែន** បានសាងឧទ្ទិសថ្វាយចំពោះព្រះពុទ្ធសាសនាក្នុងវត្តព្រះឥន្ទសាមគ្គីធម៌ និងពិធីស្រោចស្រពព្រះសុគន្ធវារីប្រគេនសម្ដេចព្រះសង្ឃនាយករងចំនួន ០២ ព្រះអង្គ នៃគណៈធម្មយុត្តិកនិកាយ នៃព្រះរាជាណាចក្រកម្ពុជា ដែលនឹងប្រព្រឹត្តទៅនៅថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០១៨ ត្រូវនឹងថ្ងៃអង្គារ ១៤ កើត ខែបឋមាសាឍ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២ ក្នុងបរិវេណវត្តព្រះឥន្ទសាមគ្គីធម៌ ស្ថិតនៅក្នុងភូមិត្រពាំងក្រពើ ឃុំក្រាំងម្កាក់ ស្រុកអង្គស្នួល ខេត្តកណ្ដាល ដែលមានសមាសភាពដូចខាងក្រោម ៖

១. សម្ដេចព្រះអភិសិរីសុគន្ធាមហាសង្ឃរាជាធិបតីកិត្តិឧទ្ទេសបណ្ឌិត **បួរ គ្រី** ព្រះប្រធានកិត្តិយស

| | | |
|---|---|---|
| ២. ឯកឧត្ដមទេសរដ្ឋមន្ត្រី | **ហ៊ឹម ឆែម** | ប្រធាន |
| ៣. សម្ដេចព្រះមង្គលទេព្វាចារ្យ | **ខឹម សុវណ្ណ** [illegible] | អនុប្រធានអចិន្ត្រៃយ៍ |
| ៤. ឯកឧត្ដម | **ឃុយ ស៊ីនឡេង** | អនុប្រធាន |
| ៥. ឯកឧត្ដម | **ខង់វី ចិស្សុក** | អនុប្រធាន |

www.pheakdeylaw.com

| | | |
|---|---|---|
| ៦. ឯកឧត្តម | **ហ៊ុន ស៊ីថា** | សមាជិក |
| ៧. ឯកឧត្តម | **ឈិន កេតនា** | សមាជិក |
| ៨. ឯកឧត្តម | **ម៉ូន លឹមហេង** | សមាជិក |
| ៩. ឯកឧត្តម | **ញ៉ែម វ៉ាលី** | សមាជិក |
| ១០. ឯកឧត្តម | **កែ សំអឿន** | សមាជិក |
| ១១. លោកជំទាវ | **នុច សុគន្ធ** | សមាជិកា |
| ១២. ឯកឧត្តម | **ម៉ៅ តិរុណា** | សមាជិក |
| ១៣. ឯកឧត្តមនាយឧត្តមសេនីយ៍ | **ខេង សាមេត** | សមាជិក |
| ១៤. ឯកឧត្តម | **សោម រតនា** | សមាជិក |
| ១៥. ឯកឧត្តម | **ជា ណារ៉េត** | សមាជិក |

**ប្រការ ២ ៖** គណៈកម្មការនេះ មានភារកិច្ចដូចតទៅ ៖

- សហការជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធ និងគណៈសង្ឃនាយក នៃគណៈធម្មយុត្តិកនិកាយ នៃព្រះរាជាណាចក្រកម្ពុជា ដើម្បីរៀបចំពិធីបុណ្យតាមប្រពៃណីព្រះពុទ្ធសាសនា ឲ្យប្រព្រឹត្តទៅបានល្អប្រសើរ
- ពិនិត្យ និងលើកសំណើដោះស្រាយរាល់បញ្ហានានា ទាក់ទិននឹងការរៀបចំពិធីបុណ្យខាងលើ
- រៀបចំកិច្ចការពារសន្តិសុខ សណ្តាប់ធ្នាប់ និងចរាចរណ៍ក្នុងពិធីបុណ្យឲ្យបានល្អប្រសើរ
- ធ្វើលិខិតអញ្ជើញ រៀបចំទទួលបដិសណ្ឋារកិច្ចថ្នាក់ដឹកនាំ និងភ្ញៀវដែលអញ្ជើញចូលរួម
- លើកគម្រោង និងចាត់ចែងគ្រប់គ្រងចំណូល ចំណាយថវិកាជាតិ និងសប្បុរសជន ក្នុងការបម្រើឲ្យពិធីបុណ្យ ប្រព្រឹត្តទៅបានដោយរលូន និងល្អប្រសើរ
- បំពេញភារកិច្ចជាក់ស្តែងផ្សេងទៀត តាមការចាំបាច់សម្រាប់បម្រើឲ្យពិធីបុណ្យ ។

**ប្រការ ៣ ៖** គណៈកម្មការនេះ អាចបង្កើតអនុគណៈកម្មការ និងក្រុមការងារបន្ថែមជាជំនួយការ និងប្រើប្រាស់មន្ត្រីក្រោមឱវាទ តាមការចាំបាច់ ដើម្បីធានាឲ្យការរៀបចំពិធីបុណ្យ ប្រព្រឹត្តទៅតាមប្រពៃណីព្រះពុទ្ធសាសនា ឲ្យបានល្អប្រសើរ ។ គណៈកម្មការនេះ អាចប្រើប្រាស់ត្រាក្រសួងធម្មការ និងសាសនា ដើម្បីដំណើរការសកម្មភាពការងាររបស់ខ្លួន ។

**ប្រការ ៤ ៖** រដ្ឋមន្ត្រីស្តីទីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងធម្មការ និងសាសនា រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង-ស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួន ដូចមានចែងក្នុងប្រការ ១ ខាងលើ ត្រូវអនុវត្តសេចក្តីសម្រេចនេះឲ្យមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ថ្ងៃអង្គារ ៦កើត ខែបឋមាសាឍ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២

ធ្វើនៅភ្នំពេញ ថ្ងៃទី ១៩ ខែមិថុនា ឆ្នាំ២០១៨

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

***អន្លែងទទួល***

- *គណៈសង្ឃនាយក នៃគណៈធម្មយុត្តិកនិកាយ នៃព្រះរាជាណាចក្រកម្ពុជា*
- *ទីស្តីការគណៈរដ្ឋមន្ត្រី*
- *ក្រសួងមហាផ្ទៃ*
- *ក្រសួងការពារជាតិ*
- *ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ*
- *ក្រសួងធម្មការ និងសាសនា*
- *ខុទ្ទកាល័យសម្តេចតេជោ នាយករដ្ឋមន្ត្រី*
- *គណៈកម្មាធិការជាតិរៀបចំបុណ្យជាតិ-អន្តរជាតិ*
- *សាលាខេត្តកណ្តាល*
- *រាជកិច្ច*
- *ដូចប្រការ ៤ "ដើម្បីអនុវត្ត"*
- *ឯកសារ កាលប្បវត្តិ*

www.pheakdeylaw.com